# អំពីការមកពិនិត្យវាយតម្លៃរបស់អ្នក

## ឯកសារនេះរួមបញ្ចូលព័ត៌មានអំពីអ្វីដែលកើតឡើងនៅពេលដែលអ្នកត្រូវបានស្នើសុំឱ្យត្រឡប់មកគ្លីនិក BreastScreen Victoria វិញដើម្បីធ្វើតេស្តបន្ថែម។

### ហេតុអ្វីបានជាខ្ញុំត្រូវបានស្នើសុំឱ្យត្រឡប់មកវិញដើម្បីធ្វើតេស្តបន្ថែម?

យើងបានស្នើសុំឱ្យអ្នកត្រឡប់មកគ្លីនិក BreastScreen Victoria វិញដើម្បីធ្វើតេស្តបន្ថែម ពីព្រោះមានផ្នែកមួយនៅលើការថតពិនិត្យដោះរបស់អ្នក (ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្ស) ដែលត្រូវការការពិនិត្យបន្ថែម។ យើងសំដៅទៅការពិនិត្យនេះថាជាការវាយតម្លៃ។ អតិថិជនភាគច្រើនដែលត្រូវបានហៅត្រឡប់មក BreastScreen Victoria  វិញមិនមានជំងឺមហារីកដោះទេ។

### តើការធ្វើតេស្តបន្ថែមនឹងត្រូវចំណាយអស់ប៉ុន្មាន?

នៅ BreastScreen Victoria យើងផ្តល់ជូនការធ្វើតេស្តបន្ថែមទាំងអស់មិនគិតថ្លៃទេ។

### តើខ្ញុំអាចនិយាយជាមួយអ្នកណាមុនការណាត់ជួបរបស់ខ្ញុំ?

អ្នកអាចនិយាយទៅកាន់គិលានុបដ្ឋាកផ្តល់ការប្រឹក្សាដែលបានឆ្លងកាត់ការបណ្តុះបណ្តាលមុនការណាត់ជួបរបស់អ្នក។ សូមទូរសព្ទទៅគ្លីនិកវាយតម្លៃរបស់អ្នកដោយផ្ទាល់។ យើងបានដាក់លេខទូរសព្ទដែលពាក់ព័ន្ធនៅក្នុងលិខិតវាយតម្លៃទាំងអស់។

### តើនឹងមានអ្វីកើតឡើងនៅកន្លែងណាត់ជួបរបស់ខ្ញុំ?

នៅពេលអញ្ជើញមកដល់គ្លីនិកវាយតម្លៃ អ្នកនឹងជួបគិលានុបដ្ឋាកផ្តល់ការប្រឹក្សាម្នាក់ដែលនឹងពន្យល់ពីអ្វីដែលនឹងកើតឡើង។ អ្នកនឹងត្រូវបានស្នើសុំឱ្យអាន និងចុះហត្ថលេខាលើទម្រង់បែបបទយល់ព្រមមួយ ដើម្បីឱ្យក្រុមវាយតម្លៃអាចបំពេញកិច្ចការធ្វើតេស្តចាំបាច់នានា។ គិលានុបដ្ឋាកផ្តល់ការប្រឹក្សានឹងឆ្លើយសំណួរទាំងឡាយណាដែលអ្នកអាចមានអំពីទម្រង់បែបបទយល់ព្រម និងដំណើរការវាយតម្លៃ។ បន្ទាប់មក ក្រុមអ្នកឯកទេសនឹងវាយតម្លៃផ្នែកម្ខុំដោះរបស់អ្នក ដែលត្រូវការការពិនិត្យ។

ក្រុមវាយតម្លៃនឹងជួយអ្នក រហូតដល់ចប់ដំណើរនៃការមកពិនិត្យរបស់អ្នក។

### តើការណាត់ជួបរបស់ខ្ញុំត្រូវចំណាយពេលប៉ុន្មាន?

សូមទុកពេលកន្លះថ្ងៃនៅគ្លីនិកវាយតម្លៃសម្រាប់ការណាត់ជួបរបស់អ្នក។ យើងអាចផ្តល់សំបុត្របញ្ជាក់ពីការមកពេទ្យសម្រាប់កន្លែងធ្វើការរបស់អ្នក។

### តើខ្ញុំនឹងត្រូវការធ្វើតេស្តអ្វីខ្លះ?

អ្នកនឹងត្រូវការធ្វើតេស្តមួយចំនួន ឬទាំងអស់ខាងក្រោមនេះ៖

- **ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សវិមាត្រ3 (3D Mammograms)** – យើងប្រើប្រភេទការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សកម្រិតខ្ពស់នៅគ្លីនិកវាយតម្លៃរបស់យើង ដើម្បីទទួលបានរូបភាពលម្អិតបន្ថែមទៀតនៃផ្នែកម្ខុំដោះដែលតម្រូវឱ្យមានការពិនិត្យ។ នេះត្រូវបានគេហៅថា ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សវិមាត្រ3 ឬ  tomosynthesis។ ការថតពិនិត្យដោះដោយប្រើកាំរស្មីអិក្សវិមាត្រ3 ផ្តិតយករូបភាពកាំរស្មីអិក្សមួយចំនួន (ជាធម្មតា 11-25) ពីមុំផ្សេងៗគ្នា ហើយរៀបចំវាឡើងវិញដើម្បីបង្កើតរូបភាពវិមាត្រ3 (3D) មួយ។
- **ការថតអេកូ ឬអ៊ុលត្រាសោនដោះ** – យើងអាចប្រើអ៊ុលត្រាសោនដើម្បីមើលជាលិកាដោះរបស់អ្នកឱ្យកាន់តែលម្អិត។ ដើម្បីថតអ៊ុលត្រាសោន យើងលាបជែលលើដោះ ហើយសង្កត់ប្រដាប់ស្ទង់រកមួយលើស្បែករបស់អ្នក។ អ៊ុលត្រាសោនមិនគួរបង្កឱ្យមានការឈឺចាប់ ឬគ្មានផាសុកភាពនោះទេ។
- **ការពិនិត្យដោះ** – វេជ្ជបណ្ឌិតអាចពិនិត្យរកមើលការប្រែប្រួលណាមួយនៅក្នុងដោះដែលពួកគេអាចមើលឃើញ ឬស្ទាបដឹង។
- **ការធ្វើកោសល្យវិច័យបណ្តូលដោះ** – វេជ្ជបណ្ឌិតអាចប្រើម្ជុលដើម្បីយកគំរូកោសិកា ឬជាលិកាតូចមួយពីផ្នែកនៃដោះដែលត្រូវការការពិនិត្យបន្ថែម។ អ្នកនឹងទទួលព័ត៌មានបន្ថែមអនៅពេលនោះ ប្រសិនបើអ្នកត្រូវធ្វើកោសល្យវិច័យ។

សូមពិភាក្សាអំពីកង្វល់ទាំងឡាយណា ជាមួយក្រុមវាយតម្លៃរបស់អ្នក។

### តើខ្ញុំមានជម្រើសអ្វីខ្លះ?

អ្នកអាចដកការយល់ព្រមរបស់អ្នក ហើយស្នើសុំឱ្យបញ្ឈប់ការធ្វើតេស្តនៅពេលណាក៏បាន។

### តើខ្ញុំនឹងទទួលបានលទ្ធផលនៅពេលណា?

ក្នុងករណីភាគច្រើន យើងនឹងអាចផ្តល់លទ្ធផលរបស់អ្នកនៅថ្ងៃដែលអ្នកមកធ្វើតេស្តវាយតម្លៃ។ ទោះជាយ៉ាងណាក៏ដោយ លទ្ធផលកោសល្យវិច័យអាចចំណាយពេលរហូតដល់ទៅ1សប្តាហ៍។ យើងក៏នឹងផ្ញើលទ្ធផលរបស់អ្នកមួយច្បាប់ទៅឱ្យវេជ្ជបណ្ឌិតរបស់អ្នកផងដែរ។



សូមមើលទំព័រម្ខាងទៀត →

## តើបន្ទាប់មកមានអ្វីកើតឡើង?

ប្រសិនបើយើងរកមិនឃើញសញ្ញានានានៃជំងឺមហារីកដោះនៅថ្ងៃមកធ្វើតេស្ត វាយតម្លៃរបស់អ្នកទេ យើងនឹងអញ្ជើញអ្នកឱ្យត្រឡប់មកពិនិត្យដោះជាទៀងទាត់វិញ ក្នុងរយៈពេល2ឆ្នាំ។

## ចុះបើអ្នករកឃើញជំងឺមហារីកដោះ?

យើងធ្វើរោគវិនិច្ឆ័យអតិថិជនមួយចំនួនតូចដែលមានជំងឺមហារីកដោះ បន្ទាប់ពីការធ្វើតេស្ត បន្ថែម។

ប្រសិនបើយើងរកឃើញជំងឺមហារីកដោះក្នុងអំឡុងពេលវាយតម្លៃអ្នក យើងនឹងរៀបចំឱ្យ អ្នកជួបជាមួយវេជ្ជបណ្ឌិត និងគិលានុបដ្ឋាកផ្តល់ការប្រឹក្សា ដើម្បីពិភាក្សាអំពីការរកឃើញ និងជំហានបន្តបន្ទាប់ទៀត។ បន្ទាប់មក យើងនឹងបញ្ជូនអ្នកទៅវេជ្ជបណ្ឌិតធម្មតារបស់អ្នក ដែលនឹងរៀបចំការថែទាំអ្នកជាបន្តទៅទៀត។

ជំងឺមហារីកដោះភាគច្រើនដែលបានរកឃើញក្នុងអំឡុងពេលថតពិនិត្យដោះ នៅតែស្ថិត ក្នុងដំណាក់កាលដំបូងនៅឡើយ។ បើការរកឃើញជំងឺមហារីកបានកាន់តែឆាប់នោះ ការ ព្យាបាលក៏ទំនងជាកាន់តែមានជោគជ័យ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ breastscreen.org.au

# កក់ទុកការណាត់នៅតាមគេហទំព័រ **breastscreen.org.au** ឬហៅទូរសព្ទលេខ **13 20 50**

**TTY 13 36 77** ប្រសិនបើអ្នកមានការពិបាកស្តាប់ ឬនិយាយ

សម្រាប់ព័ត៌មានបន្ថែម ឬដើម្បីប្តូរព័ត៌មានលម្អិតរបស់អ្នក សូមចូលទៅកាន់គេហទំព័រ **breastscreen.org.au** ឬហៅទូរសព្ទលេខ **13 20 50**

ដើម្បីសុំជំនួយអ្នកបកប្រែផ្ទាល់មាត់ សូមហៅទូរសព្ទលេខ **13 14 50**

ព័ត៌មានដែលបានបកប្រែ៖ **breastscreen.org.au/translations**

BreastScreen Victoria ទទួលស្គាល់ជំនួយពីរដ្ឋាភិបាលរដ្ឋវិចថូរៀ។



© 2023 BreastScreen Victoria. រក្សាសិទ្ធិគ្រប់យ៉ាង

ខែមេសា ឆ្នាំ2023 FS9/0423